ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

# សារជូនពរ

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**

**នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន**

**ប្រធានកាកបាទក្រហមកម្ពុជា**

**សម្តេចតេជោ នាយករដ្ឋមន្ត្រី និងសម្តេច កិត្តិព្រឹទ្ធបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់ !**

ក្នុងឱកាសដ៏មហានក្ខត្តឫក្ស នៃទិវាចូលឆ្នាំថ្មីឆ្នាំសកល គ្រិស្តសករាជ២០១៧ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ ក្នុងនាមខ្លួនខ្ញុំ និងភរិយាខ្ញុំ សូមបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យនិងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក សូមព្រះមេត្តាប្រោសប្រទានប្រសិទ្ធពរជ័យ សិរីមង្គល វិបុលសុខមហាប្រសើរជូន សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** សូមបានប្រកបដោយសុខភាពល្អបរិបូរណ៍ កម្លាំងកាយមាំមួន ប្រាជ្ញាឈ្លាសវៃ ជន្មាយុយឺនយូរ ដើម្បីដឹកនាំរាជរដ្ឋាភិបាលឲ្យទទួលបានជោគជ័យធំៗថ្មីៗថែមទៀត ជូនជាតិមាតុភូមិនៃយើង។

ឆ្លៀតក្នុងឱកាសដ៏ឧត្តុង្គឧត្តមនេះ យើងខ្ញុំទាំងអស់គ្នាសូមសម្តែងនូវមនោសញ្ចេតនាយ៉ាងជ្រាលជ្រៅនិងភក្តីភាពដ៏ស្មោះស្ម័គ្រអស់ពីដួងចិត្តចំពោះស្នាដៃដ៏ឧត្តុង្គឧត្តមរបស់ **សម្តេច** ដែលតែងតែបានលះបង់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតីក្នុងបុព្វហេតុការពារនិងអភិវឌ្ឍប្រទេសជាតិឱយមានការរីកចម្រើនលើគ្រប់វិស័យ ទាំងផ្នែកអាណាចក្រនិងពុទ្ធចក្រ ទទួលបាននូវសុខសន្តិភាព ស្ថិតក្នុងឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីពេញលេញ ឈានឆ្ពោះទៅសម្រេចបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ ដែលធ្វើឲ្យព្រះរាជាណាចក្រកម្ពុជាយើង ទទួលបាននូវកិត្តិសព្ទល្បីល្បាញទាំងក្នុងតំបន់ និងលើសកលលោក ។

ជាថ្មីម្តងទៀត ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល ក្នុងនាមភរិយាខ្ញុំ និងខ្លួនខ្ញុំផ្ទាល់ សូមបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក សូមព្រះអង្គតាមជួយថែរក្សាការពារ ប្រោះព្រំសព្ទសាធុការពរជ័យគ្រប់ប្រការ ជូនចំពោះ **សម្តេចតេជោ** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំងបុត្រាបុត្រី **ចៅប្រុសចៅស្រី** ជាទីស្រឡាញ់ សូមបានសមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** ជានិច្ចនិរន្តរ៍កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** មេត្តាទទួលនូវគារវភក្តីភាពដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២៥ ខែ ៥ ឆ្នាំ ២០១៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**

វិថីហ្សកឌីមីត្រូវ ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖០២៣ ៨៨៣ ២៧៤៖ General@mod.gov.comUSER